កិច្ចតែងការ	
មុខវិជ្ជា	ចិត្តចលភាព និងសិក្សាសង្គម
ប្រធានបទ	អារម្មណ៍
ចំណងជើងមេរៀន	ល្បែងរង្វង់ទឹកមុខ
កម្រិត	ទាប
វិជ្ជាសម្បទា	ប្រាប់ពីរបៀបវិធីដើរ ប្រាប់ពីអារម្មណ៍
បំណិនសម្បទា	អាចបង្ហាញពីការធ្វើទឹកមុខ នៅពេលដែលមានអារម្មណ៍ផ្សេងៗពីគ្នា
ចរិយាសម្បទា	សប្បាយរីករាយ និងចូលចិត្តក្នុងការធ្វើចលនាប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព
គ្រូបង្រៀន	សម្រេចចិត្តថាតើអារម្មណ៍មួយណាដែលអ្នកចង់បង្រៀនទៅក្មេងៗ ដូចជា៖ សប្បាយរីករាយ ក្រៀមក្រំ ភ័យខ្លាច ខឹង រំភើប -ល-
កុមារ	
សម្ភារ	B1-AT-12-2-1_កាតអារម្មណ៍_ពណ៌ B1-AT-12-2-2_កាតអារម្មណ៍_ខ្មៅ-ស

សកម្មភាពគ្រូបង្រៀន	សកម្មភាពសិស្ស
1. ឱ្យក្មេងៗទាំងអស់ឈរនៅខាងមុខអ្នក បន្ទាប់មកធ្វើទឹកមុខមួយណាដែលអ្នកគិតថាចង់បង្ហាញពួកគេក្នុងកាតអារម្មណ៍	1. ស្តាប់ដោយប្រុងប្រយ័ត្នអ្វីដែលដែលគ្រូនិយាយ 2. បង្ហាញអារម្មណ៍ផ្សេងៗពីគ្នា 3. ឈរជារង្វង់មូល

និងប្រើភាសាកាយវិការដើម្បីបង្ហាញពីអារម្មណ៍ដែលអ្នកបានជ្រើសរើសនៅក្នុងល្បែងមួយនោះ 2. រំលឹកក្មេងៗថាមិនត្រូវប្រើជាសម្លេងនោះទេ។ គ្រាន់តែនិយាយដោយគ្មានសម្លេងជាមួយការលេងទឹកមុខ និងភាសាកាយវិការក្នុងការពន្យល់តែប៉ុណ្ណោះ 3. សុំឱ្យក្មេងៗទាំងនោះបង្ហាញទឹកមុខ និងកាយវិការដោយខ្លួនរបស់ពួកគេផ្ទាល់ 4. បែងចែកក្មេងៗទៅជាក្រុមៗដែលមានចំនួនស្មើរៗគ្នា (វាមិនអីទេ ប្រសិនបើក្រុមមួយណាដែលចំនួនក្មេងសេស)។ ប្រសិនបើពួកគេនៅតូចៗ បង្កើតជាក្រុមតូចបាន និងក្មេងៗណាដែលរៀងធំហើយអាចបង្កើតជាក្រុមធំដែរ 5. ចែកកាតអារម្មណ៍ទៅកាន់ក្មេងៗម្នាក់មួយសន្លឹកៗ។ 6. ក្មេង២នាក់ក្នុងក្រុមនីមួយៗគួរតែមានកាតអារម្មណ៍ដូចគ្នា។ ប្រសិនបើក្រុមណាដែលមានចំនួនសេសនោះក្មេង៣នាក់អាចមានកាតអារម្មណ៍ដូចគ្នាបាន 7. ឱ្យក្រុមនីមួយឈរជារង្វង់ 8. និយាយអារម្មណ៍មួយក្នុងអារម្មណ៍ទាំងអស់	4. ផ្តោតអារម្មណ៍ និងយកចិត្តទុកដាក់នៅពេលដែលគ្រូប្រាប់អ្នកទាំងអស់គ្នាថាតើអារម្មណ៍មួយណាដែលត្រូវធ្វើ 5. នៅពេលដែលគ្រូនិយាយពីអារម្មណ៍របស់សិស្សណាម្នាក់ សិស្សម្នាក់នោះត្រូវបង្ហាញវាខណៈពេល ដែលអ្នកកំពុងផ្លាស់ប្តូរកន្លែងជាមួយនឹងក្មេងដែលមានអារម្មណ៍ដូចអ្នក។

9. សុំឱ្យក្មេងៗដែលមានកាតអារម្មណ៍ដែលបានចែកឱ្យទាំងនោះ បង្ហាញទឹកមុខរបស់ខ្លួនអោយដូចទៅនឹងកាតអារម្មណ៍ដែលមាន និងកាយវិការរបស់ពួកគេ។ នៅពេលដែលពួកគេកំពុងធ្វើវា ពួកគេអាចផ្លាស់ប្តូរកន្លែងគ្នានៅក្នុងរង្វង់នោះតែម្តង។ 10. គ្រូបន្តនិយាយទឹកមុខទាំងនោះរហូតដល់ក្មេងៗទាំងអស់បានឮទឹកមុខរបស់ពួកគេ ហើយក្មេងៗទាំងអស់បានផ្លាស់ប្តូរកន្លែងគ្នាជាការស្រេច។	